# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៧៤ សហវ.សន

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ:** សំណើសុំបុរេប្រទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយមេភូមិពោធិ៍ និងសាងសង់សំណង់សិល្បការ ស្ថិតនៅឃុំចិញ្ជ្រឹម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- លិខិតលេខ ០៨៣ ធទឧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ចំនួន ៩៦០.០០០.០០០រៀល (ប្រាំបួនរយហុកសិបលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្ម ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយមេភូមិពោធិ៍ និងសាងសង់សំណង់សិល្បការ ស្ថិតនៅឃុំចិញ្ជ្រឹម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មានដូចខាងក្រោម:

| | |
|---|---|
| - ស្តារប្រឡាយមេភូមិពោធិ៍ | ប្រវែង ១.៧០០ម |
| - សាងសង់សំណង់បង្ហៀរលើមាត់កស្បិណខាងលិច | ចំនួន ០១កន្លែង |
| - សាងសង់សំណង់លូ ២ជួរ លើប្រឡាយមេអ្នកតាជ័យ | ចំនួន ០១កន្លែង |
| - សាងសង់សំណង់លូជ្រុង ទ្វារ១ លើប្រឡាយមេអ្នកតាជ័យ | ចំនួន ០២កន្លែង |
| - សាងសង់សំណង់លូមូលដោះទឹក លើប្រឡាយមេអ្នកតាជ័យ | ចំនួន ០២កន្លែង |
| - សាងសង់សំណង់លូជ្រុង ទ្វារ១ លើប្រឡាយមេបាក់អាយ | ចំនួន ០២កន្លែង |
| - សាងសង់សំណង់ជ្រុង ទ្វារ១ លើប្រឡាយមេភូមិពោធិ៍ | ចំនួន ០៤កន្លែង |
| - សាងសង់សំណង់លូមូលដោះទឹក លើប្រឡាយមេភូមិពោធិ៍ | ចំនួន ០២កន្លែង |

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ដោយឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ »
- ឯកសារ-កាលប្បវត្តិ